# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jul-2012, 15:04
CMS/CFO: Uch Arun

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសង |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ** ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ចំនួន១៦

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី១-១៦

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធួ មណី

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Elisabeth SIMONNEAU FORT

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្ដម
លោក Michael G.KARNAVAS
លោក គង់ សំអុន
លោក Jacques VERGÈS

លោក Arthur VERCKEN
Anta GUISSE

## ១. សេចក្ដីផ្ដើម

១- នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានចេញ *សេចក្ដីសម្រេចរបស់ខ្លួន លើសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ទាក់ទងនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារផ្សេងទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (“សេចក្ដីសម្រេច”)*[1]។ សេចក្ដីសម្រេចនេះបានអនុញ្ញាតឲ្យទទួលយក “ភ័ស្ដុតាងក្នុងទម្រង់ជាកំណត់ហេតុ ឬប្រតិចារឹកជាលាយលក្ខណ៍អក្សរ... បើសិនជា [ភ័ស្ដុតាងនោះ] បានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងវាក្យខណ្ឌទី៤.២ និង ៤.៣ នៃសេចក្ដីសម្រេច[នេះ]”[2]។ លក្ខណៈវិនិច្ឆ័យនេះ រួមបញ្ចូលនូវកម្រិតដែលអាចធ្វើឲ្យភ័ស្ដុតាងកាន់តែមានអានុភាព ដែលរួមមានទាំងសក្ខីកម្មផ្ទាល់មាត់ ភាពពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗនៅពេលសវនាការ និងភាពជឿទុកចិត្តបាន[3]។ ចំពោះភ័ស្ដុតាងដែលមាននៅក្នុងកំណត់ហេតុ ឬប្រតិចារឹកទាំងនេះដែលពាក់ព័ន្ធទៅនឹងសកម្មភាព ឬអំពើរបស់ជនជាប់ចោទ អង្គជំនុំជម្រះបានសម្រេចថា ភ័ស្ដុតាងនោះមិនអាចទទួលយកសម្រាប់គោលបំណងនេះទេ អាស្រ័យដោយសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ របស់ជនជាប់ចោទតម្រូវថា មេធាវីការពារក្ដីត្រូវបានអនុញ្ញាតឲ្យចោទសំណួរផ្សេងៗដល់សាក្សីអំពីបញ្ហាទាំងនោះ[4]។

២- ដោយអនុលោមតាមសេចក្ដីសម្រេចនេះ សហព្រះរាជអាជ្ញាសូមដាក់សំណើសុំនេះ និងឧបសម្ព័ន្ធ **អមពី១ដល់១៦** ដែលកំណត់អត្តសញ្ញាណកំណត់ហេតុជាលាយលក្ខណ៍អក្សរ (រួមទាំងពាក្យបណ្ដឹង) និងប្រតិចារឹកសវនាការ ដែលពាក់ព័ន្ធទៅនឹងបញ្ហាអង្គហេតុដែលនឹងត្រូវសម្រេចនៅក្នុងសវនាការនេះ។ បើសិនជាសម្ភារៈទាំងនេះមានផ្ទុកនូវភ័ស្ដុតាងអំពីសកម្មភាព ឬអំពើផ្សេងៗរបស់ជនជាប់ចោទ សំណើនេះនឹងមិនដាក់ជូនសម្រាប់គោលបំណងនោះឡើយ ប៉ុន្តែគឺសម្រាប់គោលបំណងនៃការបញ្ជាក់អំពីបញ្ហាផ្សេងៗ ដូចបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយនេះតែប៉ុណ្ណោះ។

---

[1] **E96/7** សេចក្ដីសម្រេចលើសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ទាក់ទងនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារផ្សេងទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ២០ មិថុនា ២០១២ (“សេចក្ដីសម្រេច”)។

[2] **E96/7** សេចក្ដីសម្រេច ត្រង់កថាខណ្ឌទី៣៦។

[3] **E96/7** សេចក្ដីសម្រេច ត្រង់កថាខណ្ឌទី២០-៣៣។

[4] **E96/7** សេចក្ដីសម្រេច ត្រង់កថាខណ្ឌទី២២។

៣- គោលបំណងនៃសំណើសុំនេះ គឺដើម្បីពន្លឿនសវនាការ តាមរយៈការដាក់នៅចំពោះមុខអង្គជំនុំជម្រះ នូវភ័ស្តុតាងរបស់សាក្សីដែលពាក់ព័ន្ធ ដែលមិនមានឱកាសមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងតុលាការបាន។ ភ័ស្តុតាងទាំងនេះនឹងជួយដល់អង្គជំនុំជម្រះ នៅក្នុងការស្វែងរកការពិតចំពោះបទចោទជាច្រើនដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលជាកម្មវត្ថុនៃការជំនុំជម្រះនៅពេលបច្ចុប្បន្ននេះ។ ការទទួលយកដូច្នេះ គឺសំខាន់ណាស់ ដើម្បីឱ្យការគ្រប់គ្រងកាន់តែមានប្រសិទ្ធភាពចំពោះសវនាការមួយដែលមានទំហំដូចនេះ បើសិនជាអង្គជំនុំជម្រះត្រូវការកំណត់សម្រេចអំពីការពិតនៃការចោទប្រកាន់។ ដូចអតីតចៅក្រមនៃអង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ចៅក្រម Patricia Wald បានមានប្រសាសន៍ទាក់ទងនឹងសំណុំរឿងដែលមានទំហំស្រដៀងគ្នានេះថា "មានការជាប់ទាក់ទងគ្នាច្រើនទៅនឹងការចងក្រងចិរវេលាខ្លី ឬសករាជមួយនៃជម្លោះ...នៅថ្នាក់ជាតិ ជាជាងការបញ្ជាក់អំពីឧប្បត្តិហេតុដាច់ដោយឡែកមួយ" អាស្រ័យថា "បើសិនជាគេ [តុលាការ] ត្រូវបំពេញមុខនាទីដែលមានលក្ខណៈខុសប្លែកពីគេរបស់ខ្លួន តុលាការដូច្នេះមិនអាចតម្រូវឱ្យអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាតិជាក់លាក់ណាមួយឡើយ។ គេត្រូវតែមានការទទួលស្គាល់ឱ្យបានត្រឹមត្រូវថា ដើម្បីថែរក្សាឱ្យបាននូវការគោរពតុលាការដូច្នេះ ត្រូវតែបំពេញសកម្មភាពមិនត្រឹមតែឱ្យបានត្រឹមត្រូវយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឱ្យបានឆាប់រហ័សទៀតផង"[5]។ តាមរយៈការដាក់សំណើសុំនេះ សហព្រះរាជអាជ្ញាស្វែងរកដើម្បីធានាឱ្យប្រាកដថា សវនាការជំនុំជម្រះនេះ ពិតជាត្រឹមត្រូវយុត្តិធម៌ និងឆាប់រហ័សផងដែរ។

៤- សហព្រះរាជអាជ្ញាសន្និដ្ឋានថា ឯកសារដូចបានកំណត់អត្តសញ្ញាណក្នុងសំណើសុំនេះ បានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលយកឯកសារដែលបានកំណត់ដោយអង្គជំនុំជម្រះ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យទទួលយកកំណត់ហេតុ និងប្រតិចារឹកជាលាយលក្ខណ៍អក្សរទាំងនេះជាភ័ស្តុតាង និងផ្តល់លេខ E3 (បើសិនជាមិនទាន់បានផ្តល់លេខឯកសារនៅឡើយ)។ សហព្រះរាជអាជ្ញាសូមស្នើបន្ថែមទៀតដល់អង្គជំនុំជម្រះ ឱ្យពឹងផ្អែកទៅលើឯកសារនេះអមជាមួយនឹងសក្ខីកម្មផ្ទាល់មាត់ដែលបានស្តាប់នៅពេលសវនាការ និងភ័ស្តុតាងជាឯកសារដទៃទៀតដែលបានទទួលយករួចហើយ ក្នុងការវាយតម្លៃលើបទចោទប្រឆាំងនឹងជនជាប់ចោទនៅក្នុងសវនាការនេះ។

[5] *សូមអាន* Patricia M. Wald, "'ដើម្បីកំណត់នូវព្រឹត្តិការណ៍មិនគួរឱ្យជឿ តាមរយៈភ័ស្តុតាងដែលគួរឱ្យជឿទុកចិត្តបាន: សក្ខីកម្មថ្លែងសច្ចានៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការឧក្រិដ្ឋកម្មសង្គ្រាមនៅយូហ្គោស្លាវី", 42 Harv. Int'l L.J. 535 (2001) ត្រង់ទំព័រ ៥៣៧។

## ២. សាវតារអង្គហេតុ និង ឧបសម្ព័ន្ធ

### ក. សាវតារអង្គហេតុ

៥- នៅមុនពេល និង ភ្លាមៗ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលអនុញ្ញាតឲ្យមានការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារឹក នៅក្នុងសវនាការនៅក្រោមលក្ខខណ្ឌជាក់លាក់មួយចំនួនមក សហព្រះរាជអាជ្ញាធ្លាប់បានដាក់សំណើចំនួនពីរ សុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី សម្រាប់គោលបំណងបន្ថែមការអះអាងលើសក្ខីកម្ម ទាក់ទងនឹងដំណាក់កាលទីI[6] និងដំណាក់កាលទីII[7] នៃការជម្លៀសប្រជាជនស៊ីវិលដោយបង្ខំ ដូចបានលើកឡើងចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញចម្លើយតបមួយទៅនឹងសំណើរទាំងពីរនេះ[8] ដោយបង្គាប់ឲ្យភាគីនានាដាក់កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់ ដែលពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជន នៅដំណាក់កាលទីI និងដំណាក់កាលទីII រួមចូលគ្នា សម្រាប់ឲ្យគេទទួលយក។ ខណៈដែលសំណើរចំនួនពីរ ពីលើកមុនដែលដាក់ដោយសហព្រះរាជអាជ្ញា បានកំណត់អត្តសញ្ញាណលើកំណត់ហេតុស្តាប់ចម្លើយសាក្សីនានាដែល "ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទីI និង ទីII"[9] សំណើនេះក៏ មានរួមបញ្ចូលផងដែរនូវឯកសារនានាទាក់ទងនឹងដំណាក់កាលទាំងពីរនេះ។ កំណត់ហេតុទាំងនេះបញ្ជាក់ភស្តុតាងលើបញ្ហាដទៃទៀត ដែលជាប្រធានបទនៃសវនាការនាពេលបច្ចុប្បន្ន និងដែលចាំបាច់ក្នុងការបង្ហាញសក្ខីកម្មដល់បទចោទនានានៅក្នុងដីកាដំណោះស្រាយ[10]។

---

[6] **E208** សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១, ថ្ងៃទី១៥ មិថុនា ២០១២ ("សំណើដំណាក់កាលទីI របស់សហព្រះរាជអាជ្ញា")។

[7] **E208/2** សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យទទួលយកចម្លើយសាក្សីនានា ដែលទាក់ទងនឹងដំណាក់កាលទី២ នៃការជម្លៀសប្រជាជន និងបញ្ជីភស្តុតាងផ្សេងទៀត, ថ្ងៃទី៥ កក្កដា ២០១២ ("សំណើដំណាក់កាលទីII របស់សហព្រះរាជអាជ្ញា")។

[8] **E208/3** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ និង ទី២ (E208 និង E208/2) និង ចម្លើយតបរបស់លោក អៀង សារី (E208/1), ថ្ងៃទី១៩ កក្កដា ២០១២ ("ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង")។

[9] ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ត្រង់កថាខណ្ឌទី៣។

[10] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩ ស្ទួន, ថ្ងៃទី២២ កញ្ញា ២០១១ ត្រង់កថាខណ្ឌទី១។

## ខ. ឧបសម្ព័ន្ធ

៦- **ឧបសម្ព័ន្ធ១ និង២** មានបញ្ជីលម្អិតទាំងស្រុងអំពីកំណត់ហេតុស្តាប់ចម្លើយសាក្សី (រួមទាំងបណ្តឹងនានា និងប្រតិចារឹកសវនាការសាក្សី ជាបន្តបន្ទាប់ ដែលសហព្រះរាជអាជ្ញាសូមស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ[11]។ ដោយស្របទៅនឹងសេចក្តីសម្រេចមានតែឯកសារដែលមិនធ្លាប់បានដាក់ ឬបើមិនដូច្នោះទេ មានតែឯកសារដែលមិនត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះប៉ុណ្ណោះទេ ដែលបានដាក់នៅក្នុងសំណើនេះ។ ដូច្នេះ **ឧបសម្ព័ន្ធ១** និង **២** មិនមានរួមបញ្ចូលសាក្សីនានាដែលធ្លាប់បានផ្តល់សក្ខីកម្មនៅក្នុងតុលាការ[12] ឬដែលបច្ចុប្បន្ននេះត្រូវបានអង្គជំនុំជម្រះរៀបចំកាលវិភាគឲ្យមកផ្តល់សក្ខីកម្ម[13]។ ដើម្បីចៀសវាងនូវការច្រំដែល គេមិនត្រូវរួមបញ្ចូលនូវបុគ្គលនានាដែលកំណត់ហេតុចម្លើយរបស់ខ្លួនត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងសំណើពីលើកមុនចំនួនពីររបស់សហព្រះរាជអាជ្ញាដែលសុំឲ្យទទួលយកភ័ស្តុតាងរបស់សាក្សី ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាល ទីI[14] និង ទីII[15]។ យ៉ាងណាក៏ដោយ ដើម្បីជាប្រយោជន៍ក្នុងការដាក់បញ្ចូលគ្នានូវការដាក់ឯកសារចំនួនបី ទាក់ទងនឹងការជម្លៀសប្រជាជនស៊ីវិលដោយបង្ខំ។ **ឧបសម្ព័ន្ធ៩** យោងទៅដល់ការដាក់សំណើពីលើកមុនចំនួនពីរ ដូចដែលអង្គជំនុំជម្រះបានបង្គាប់[16]។

---

[11] ទម្រង់នេះ មានបំណងធ្វើឲ្យត្រូវតាមលក្ខខណ្ឌតម្រូវរបស់អង្គជំនុំជម្រះស្តីពីគោលបំណងជាក់លាក់សម្រាប់ការទទួលយកឯកសារនីមួយៗ។ *សូមមើល* **E96/7** សេចក្តីសម្រេច, ត្រង់កថាខណ្ឌទី៣៤។

[12] *ចូរអាន* **E1/57.1**, ប្រតិចារឹក, ថ្ងៃទី២ មេសា ២០១២ ត្រង់ទំព័រទី៨៩-៩០។ បើថាសាក្សីមានបំណងចង់មកផ្តល់សក្ខីកម្ម អង្គជំនុំជម្រះធ្លាប់បានសម្រេចថា កំណត់ហេតុស្តាប់ចម្លើយពីមុនរបស់ពួកខ្លួន ត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

[13] **E131/1** បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង, ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5, ថ្ងៃទី២៥ តុលា ២០១១។ **E172** សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង០០២/០១, ថ្ងៃទី១៧ កុម្ភៈ ២០១២។ បញ្ជីឈ្មោះសាក្សី និង ការកែប្រែជាបន្តបន្ទាប់ តាមពេលវេលា ទៅតាមកំណត់ហេតុស្តាប់ចម្លើយពីមុនរបស់ខ្លួនតម្រូវ ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ យ៉ាងណាក៏ដោយ កាលណាសាក្សី ឬ អ្នកជំនាញណាម្នាក់ ដែលបច្ចុប្បន្ននេះត្រូវបានចាត់កាលវិភាគឲ្យមកផ្តល់សក្ខីកម្មដោយអង្គជំនុំជម្រះ ដែលលែងត្រូវការគាត់ទៀត ហើយនោះ សហព្រះរាជអាជ្ញាកត់សម្គាល់ថាពួកគាត់អាចដាក់ញត្តិបន្ថែមមួយទៀតទៅនឹងញត្តិនេះ ក្នុងគោលបំណងដើម្បីដាក់បញ្ចូលកំណត់ហេតុស្តាប់ចម្លើយ និង សក្ខីកម្មសាក្សី ដែលបើមិនដូច្នោះទេ នឹងមិនត្រូវបានទទួលយកឡើយ។

[14] **E208** សំណើដំណាក់កាលទីI របស់សហព្រះរាជអាជ្ញា។

[15] **E208/2** សំណើដំណាក់កាលទីII របស់សហព្រះរាជអាជ្ញា។

[16] **E208/3** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង។

៧- ទាំង**ឧបសម្ព័ន្ធ១** និងទាំង**ឧបសម្ព័ន្ធ២** មានរួមបញ្ចូលនូវសេចក្តីលម្អិតដូចតទៅៈ (១) ឈ្មោះសាក្សីដែលបានផ្តល់កំណត់ហេតុស្តាប់ចម្លើយ ឬសក្ខីកម្មសវនាការ, (២) កាលបរិច្ឆេទនៃកំណត់ហេតុស្តាប់ចម្លើយ ឬសក្ខីកម្ម, (៣) ប្រភេទជាក់លាក់នៃឯកសារ, (៤) លេខឯកសារ E3 បើពីមុនត្រូវ បានសំអាងហេតុផល, (៥) លេខសំណុំរឿង, (៦) ចំនួនទំព័រសរុបនៃឯកសារដើម, (៧) លេខយោងភ័ស្តុតាង “ERN” សម្រាប់ការបកប្រែឯកសារជាភាសាខ្មែរ អង់គ្លេស និងបារាំង, (៨) សេចក្តីរៀបរាប់សង្ខេបអំពីឯកសារ, និង (៩) បញ្ជីបញ្ហាពាក់ព័ន្ធមួយចំនួន នៅក្នុងដីកាដំណោះស្រាយដែលទាក់ទងនឹងសវនាការលើកដំបូង ដែលកំណត់ហេតុស្តាប់ចម្លើយ ឬសវនាការ បានជួយនៅក្នុងការផ្តល់សក្ខីកម្ម[17]។

៨- **ឧបសម្ព័ន្ធចាប់ពីទី៣** ដល់ទី**១៦** (សរុបទាំងអស់១៤) គឺជាអត្ថបទនៃ**ឧបសម្ព័ន្ធទី១ និងទី២** ដែលធ្វើឲ្យមានលក្ខណៈងាយស្រួល ។ គោលបំណងនៃឧបសម្ព័ន្ធបន្ថែមថ្មីទាំង១៤នេះ គឺដើម្បីធ្វើឲ្យកាន់តែកាន់តែមានភាពច្បាស់លាស់ជាងមុន ស្តីពីបរិមាណនៃភ័ស្តុតាងដែលស៊ីសង្វាក់គ្នាដែលកំពុងតែស្នើសុំ *ផ្អែកតាមបញ្ហានីមួយៗ* ដែលផ្ទុយពី**ឧបសម្ព័ន្ធទី១** និង**ទី២** ដែលបញ្ជាក់ឲ្យដឹងពីបញ្ហាមួយចំនួនដែលពាក់ព័ន្ធ*ដែលផ្អែកតាមចម្លើយ ឬសក្ខីកម្មនីមួយៗ*។ ហេតុដូចនេះ ក្នុងករណីបើមានចម្លើយ ឬសក្ខីកម្មរបស់សាក្សីដោយឡែកណាម្នាក់ ត្រូវបានបញ្ជាក់អត្តសញ្ញាណនៅក្នុង**ឧបសម្ព័ន្ធទី១** និង**ទី២** មានជាប់ទាក់ទងទៅនឹងបញ្ហានានាជាច្រើននោះ សាក្សីនឹងត្រូវបានគេដាក់ចូលនៅក្នុងបញ្ជីនៅក្នុងគ្រប់ឧបសម្ព័ន្ធទាំងអស់ដែលពាក់ព័ន្ធទៅនឹងបញ្ហាជាច្រើនទាំងនោះ។

៩- **ឧបសម្ព័ន្ធចាប់ពីទី៣** ដល់ទី**១៦នេះ** គឺជាប់ទាក់ទងគ្នាទៅនឹងបញ្ហាជាគន្លឹះនានា ដែលជាកម្មវត្ថុនៃការជំនុំជម្រះក្តីនាពេលបច្ចុប្បន្ននេះ ដែលត្រូវបានដាក់បញ្ចូលក្នុងបញ្ជីទៅតាមលំដាប់លេខរៀងនៃឧបសម្ព័ន្ធៈ

(១) ប្រវត្តិដើមនៃកម្ពុជាប្រជាធិបតេយ្យ (“DK”)

(២) រចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មជ្ឈិម

---

[17] គេបានសន្និដ្ឋានថា អង្គហេតុនានាដែលមាននៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៅក្នុងប្រតិចារឹកដែលពាក់ព័ន្ធនឹងបញ្ហាសំខាន់ជាច្រើនដែលជាប់ទាក់ទិននឹងអង្គជំនុំជម្រះ។ ដោយហេតុដើម្បីជៀសវាងបង្កើតនូវតារាងកំណត់ហេតុ ឬប្រតិចារឹក ដែលច្រើនសម្បើមត្រូវបានកំណត់ចំណុចសំខាន់ៗបំផុតនៅក្នុងដីកាដំណោះស្រាយនោះ។

(៣) រចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យនៅថ្នាក់ជាតិ

(៤) រចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងរបស់កម្ពុជាប្រជាធិបតេយ្យ

(៥) រចនាសម្ព័ន្ធផ្នែកយោធារបស់កម្ពុជាប្រជាធិបតេយ្យ

(៦) ជម្លោះប្រដាប់អាវុធដែលកម្ពុជាប្រជាធិតេយ្យបានចូលរួមនៅក្នុងនោះ

(៧) សហកម្មឧក្រិដ្ឋកម្មរួម ("JCE") គោលនយោបាយក្នុងការជម្លៀសប្រជាជន

(៨) សហកម្មឧក្រិដ្ឋកម្មរួម ("JCE") គោលនយោបាយក្នុងការបង្កើតនូវការដ្ឋាន និងសហករណ៍នានា

(៩) សហឧក្រិដ្ឋកម្មរួម ("JCE") គោលនយោបាយក្នុងការបង្កើតនូវមន្ទីរសន្តិសុខ និងទីកន្លែងសម្រាប់សម្លាប់នានា

(១០) សហកម្មឧក្រិដ្ឋកម្មរួម ("JCE") គោលនយោបាយដើម្បីផ្តោតមុខសញ្ញាទៅលើក្រុមជនមួយចំនួន

(១១) សហកម្មឧក្រិដ្ឋកម្មរួម ("JCE") គោលនយោបាយទាក់ទងនឹងការធ្វើបាបពុទ្ធសាសនិកជន

(១២) សហកម្មឧក្រិដ្ឋកម្មរួម ("JCE") គោលនយោបាយទាក់ទងនឹងការធ្វើបាបជនជាតិចាម

(១៣) សហកម្មឧក្រិដ្ឋកម្មរួម ("JCE") គោលនយោបាយទាក់ទងនឹងការធ្វើបាបជនជាតិវៀតណាម និង

(១៤) សហកម្មឧក្រិដ្ឋកម្មរួម ("JCE") គោលនយោបាយការគ្រប់គ្រងលើអាពាហ៍ពិពាហ៍

១០- នៅក្នុងការចាប់ផ្តើមនៃឧបសម្ព័ន្ធនីមួយៗ ចាប់តាំងពីទី៣ ដល់ទី**១៦** សហព្រះរាជអាជ្ញាបានបញ្ជាក់អត្តសញ្ញាណសាក្សីនានាដែលបានផ្តល់សក្ខីកម្មរួចហើយ នៅក្នុងពេលសវនាការនេះលើបញ្ហាជាពិសេសដែលជាកម្មវត្ថុនៃឧបសម្ព័ន្ធ។ សក្ខីកម្មរបស់សាក្សីដែលបានកំណត់ពេលរួចហើយ ហើយដែលមិនទាន់បានស្តាប់សវនាការនៅឡើយ មិនបានដាក់បញ្ចូលទេ។ យ៉ាងណាមិញ គេរំពឹងថាសាក្សី និងអ្នកជំនាញនៅសល់ទាំងប៉ុន្មាននេះដែលបានកំណត់កាលវិភាគមកផ្តល់សក្ខីកម្ម ដោយអង្គជំនុំជម្រះដោយត្រួតគ្នា គ្របដណ្តប់លើបញ្ហាទាំង១៤ ដែលនៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ និងសក្ខីកម្មដែលត្រូវបានផ្តល់អត្តសញ្ញាណមានទាក់ទងនឹងបញ្ហាទាំងនេះ។

១១- ដើម្បីងាយស្រួលក្នុយការកំណត់អត្តសញ្ញាណទីកន្លែងរបស់សាក្សី ក្នុងការផ្តល់ភស្តុតាងស៊ីសង្វាក់គ្នាលើបញ្ហាទាំងឡាយដែលមាននៅក្នុង**ឧបសម្ព័ន្ធចាប់តាំងពីទី១៣ ដល់ទី១៦**នោះ ឧបសម្ព័ន្ធនីមួយៗត្រូវ

បានរៀបចំដាក់តម្រៀប ជាដំបូងគេបង្អស់គឺទៅតាមប្រភេទនៃឯកសាររបស់សាក្សី ទីពីរ គឺទៅតាមការដាក់បញ្ចូលរបស់ខ្លួនកាលពីលើកមុននៅក្នុងបញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា និងជាបន្ទាប់មកទៀត គឺទៅតាមលំដាប់លំដោយនៃអក្ខរក្រម។

១២- ប្រសិនជាចាំបាច់ នៅក្នុងរង្វង់នៃឧបសម្ព័ន្ធទាំងនេះ សាក្សីទាំងឡាយត្រូវបានធ្វើការបែងចែកឲ្យទៅជាបញ្ហាតូចៗជាបន្ទាប់ទៀត ដែលឯកសារភ័ស្តុតាងរបស់សាក្សីទាំងនេះ គឺជាអ្នកជួយនៅក្នុងការបង្ហាញសក្ខីកម្ម។ បញ្ហាតូចៗជាបន្ទាប់ទៀតមួយចំនួនក្នុងនោះដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនានាមិនត្រូវបានគេដាក់បញ្ចូលជាក់លាក់ទៅក្នុងសំណុំរឿងលេខ០០២/០១ទេ ក៏ប៉ុន្តែបញ្ហាដែលពាក់ព័ន្ធដោយសារវាជួយ ក្នុងការបង្ហាញការពិតអំពីអត្ថិភាពនៃគោលនយោបាយនានានៃសហកម្មឧក្រិដ្ឋកម្មរួម និងអំពីលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលតាមដូចដែលលក្ខខណ្ឌបានតម្រូវដើម្បីចោទប្រកាន់នៅក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ហើយក៏មានការបញ្ជាក់ផងដែរនៅក្នុងឧបសម្ព័ន្ធនីមួយៗដែលជនណាម្នាក់ ដែលនៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ឬសក្ខីកម្មរបស់ខ្លួនមានភ័ស្តុតាងជាព័ត៌មានទាក់ទងអំពីសកម្មភាព ឬអំពីការប្រព្រឹត្តិរបស់ជនជាប់ចោទ។ នេះគឺត្រូវបានដាក់សម្គាល់ដោយការកំណត់ដូចតទៅនេះ៖ “**[a&c]**”។ ដូចដែលបានបញ្ជាក់រួចហើយពីខាងដើម កំណត់ហេតុស្តាប់ចម្លើយសាក្សី ឬប្រតិចារឹកដែលកំពុងតែដាក់ជូនក្នុងពេលនេះ គឺមិនមែនក្នុងគោលបំណងនោះឡើយ ប៉ុន្តែគឺដើម្បីបង្ហាញភ័ស្តុតាងអំពីបញ្ហាដទៃទៀតនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលជាប្រធានបទនៃការជំនុំជម្រះក្តីលើកទីមួយនេះ។

១៣- អាស្រ័យហេតុនេះ **ឧបសម្ព័ន្ធ**ចាប់ពី**ទី៣** ដល់**ទី១៦** គឺទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ និងសក្ខីកម្មតែមួយដដែល ដូចនៅក្នុង**ឧបសម្ព័ន្ធទី១** និង**ទី២** គឺជាអនុឈុតមួយ និងជាការបំពេញបន្ថែមទៅលើបញ្ជីឯកសារកាលពីមុន ដែលបានដាក់ដោយសហព្រះរាជអាជ្ញាកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១[18] និងជាបន្ទាប់មកទៀត នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១[19]។

## III. អំពីលក្ខណៈ វិនិច្ឆ័យសម្រាប់ទទួលយក

[18] ឯកសារលេខ **E9/31** បញ្ជីឯកសារសំរាប់សវនាការរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៩ មេសា ២០១១។

[19] ឯកសារលេខ **E109/4** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំឯកសារដែលទាក់ទងនឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី, ២២ កក្កដា ២០១២។

១៤- ផ្អែកតាមស្មារតីនៃលក្ខណៈកំណត់ហេតុស្តាប់ចម្លើយសាក្សី និងសក្ខីកម្មសាក្សីដែលបានស្នើសុំឱ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលយក និងកត្តាផ្សេងៗសម្រាប់គាំទ្រដល់ការទទួលយក ឥឡូវនេះនឹងត្រូវបានដោះស្រាយ។ លក្ខណៈវិនិច្ឆ័យ និងកត្តានានា គឺរួមបញ្ចូលទាំងលក្ខខណ្ឌតម្រូវដែលថាឯកសារទាំងឡាយ (១) ត្រូវតែបង្ហាញសក្ខីកម្មអំពីបញ្ហាផ្សេងៗវិញ ប្រសើរជាងការបង្ហាញអំពីអំពើ ឬការប្រព្រឹត្តិរបស់ជនជាប់ចោទ (២) ត្រូវតែជាចម្លើយផ្ទាល់មាត់ដែលមានលក្ខណៈត្រួតគ្នា (៣) និង/ឬទាក់ទងទៅនឹងផលប៉ះពាល់របស់ឧក្រិដ្ឋកម្មទាំងនេះទៅលើជនរងគ្រោះ (៤) ត្រូវតែបំពេញគ្រប់ទៅតាមបទដ្ឋានស្តីពីភាពគួរឱ្យជឿទុកចិត្តបានសម្រាប់ការទទួលយក។

## ក. ឯកសារទាំងឡាយត្រូវតែជាសក្ខីកម្មផ្ទាល់មាត់របស់សាក្សីដែលមានលក្ខណៈត្រួតគ្នា និងដែលទាក់ទងទៅនឹងបញ្ហាផ្សេងៗទៀតក្រៅពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ

១៥- នៅក្នុងសេចក្តីសម្រេច អង្គជំនុំជម្រះបានសម្រេចថា អនុលោមតាមយុត្តិសាស្ត្រ និងការអនុវត្តនានារបស់អន្តរជាតិដែលពាក់ព័ន្ធកត្តាទាំងឡាយដែលគាំទ្រដល់ការទទួលយក និងការផ្តល់នូវតម្លៃជាភស្តុតាងភាពមួយចំនួន ហើយដែលនាំឱ្យមានការផ្តល់ទម្ងន់ចំពោះកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ឬប្រតិចារឹក គឺរួមបញ្ចូលអំពីថាតើភស្តុតាងនោះ “(ក)មានលក្ខណៈត្រួតគ្នាដែរ ឬទេនៅក្នុងចម្លើយដែលសាក្សីផ្សេងៗទៀតនឹងត្រូវផ្តល់ ឬបានផ្តល់សក្ខីកម្មដោយផ្ទាល់មាត់រួចហើយអំពីអង្គហេតុស្រដៀងៗគ្នានេះ” (ខ) តើមានជាប់ទាក់ទងទៅនឹងប្រវត្តិដើម ប្រវត្តិសាស្ត្រនយោបាយ ឬយោធា, មានពាក់ព័ន្ធគ្នាជាមួយនឹងភស្តុតាងស្តីពីទីតាំងឧក្រិដ្ឋកម្ម ឬក្លាយទៅជាភស្តុតាងស្តីពីធាតុផ្សំសម្រាប់ការចាប់ផ្តើមនៃឧក្រិដ្ឋកម្មអន្តរជាតិ (ដូចជា អំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិណាមួយ ឬអំពីលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនៃការវាយប្រហារណាមួយ)ដែរ ឬទេ?[20]។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ចំពោះយុត្តិសាស្ត្ររបស់តុលាការ ICTY ដែល

[20] ឯកសារលេខ **E96/7** សេចក្តីសម្រេច, ត្រង់កថាខណ្ឌទី២៤។

ជាប្រភេទអាចទទួលយកបាននៃភស្តុតាង ក៏មានរួមបញ្ចូលទាំង "គោលនយោបាយទូទៅ រចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទង និងអត្ថិភាពនៃផែនការឧក្រិដ្ឋកម្មរួម" ផងដែរ[21]។

១៦- ក៏ប៉ុន្តែ អង្គជំនុំជម្រះបានសម្រេចថា "កំណត់ហេតុស្តាប់ចម្លើយសាក្សី ឬប្រតិចារឹកដែលបានស្នើសុំឲ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងដែលក្លាយទៅជាភ័ស្តុតាងអំពីអំពើ ឬការប្រព្រឹត្តិរបស់ជនជាប់ចោទណាមួយដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ដែលអាស្រ័យទៅតាមករណីលើកលែងដែលមានកម្រិតកំណត់មួយចំនួន គឺត្រូវតែ "មិនអាចឲ្យទទួលយកបានសម្រាប់គោលបំណងនេះឡើយ"[22]។ នៅករណីនេះ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញមានភាពខុសគ្នាមួយ[23] រវាង"អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ" និងគោលនយោបាយ និងរចនាសម្ព័ន្ធទូទៅនានាដែលរួមទាំងប្រវត្តិដើមខាងអង្គហេតុនៃឧក្រិដ្ឋកម្មនានា "ដែលមិនជាប់ទាក់ទងជិតស្និទ្ធជាមួយនឹងជនជាប់ចោទ"[24] នៅក្នុងយុត្តិសាស្ត្រតុលាការ ICTY។ លើសពីនេះ លើបញ្ហាស្តីពីការដឹងរបស់ជនជាប់ចោទ អំពីឧក្រិកម្មនានា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការICTY នៅក្នុងករណីរឿក្តីរបស់ *Galić* បានាសម្រេចថា ទោះបីជាភ័ស្តុតាងដែលមិនបានលើកឡើងដោយចំៗអំពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទនោះក៏ដោយ ក៏អាចបង្ហាញសក្ខីកម្មអំពីអត្ថិភាពនៃគំរូជាតួយ៉ាងនៃឧក្រិដ្ឋកម្មណាមួយ ដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់បង្ហាញភ័ស្តុតាងថា ជនជាប់ចោទ "*ត្រូវតែ*បានដឹងថាអំពើរបស់ខ្លួនផ្ទាល់(ដែលបានបង្ហាញការពិតដោយសក្ខីកម្មផ្ទាល់មាត់) គឺត្រូវគ្នាជាមួយនឹងគំរូជាតួយ៉ាងនោះដែរ"[25]។

១៧- អាស្រ័យហេតុនេះ អនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ សហព្រះរាជអាជ្ញាមិនស្នើសុំថា កំណត់ហេតុស្តាប់ចម្លើយសាក្សី ឬសក្ខីកម្មសាក្សីត្រូវតែបានទទួលយកដោយមិនចាំបាច់មានការ

---

[21] ឯកសារលេខ **E96/7** សេចក្តីសម្រេច, ត្រង់កថាខណ្ឌទី២១។

[22] ឯកសារលេខ **E96/7** សេចក្តីសម្រេច, ត្រង់កថាខណ្ឌទី២២។

[23] ឯកសារលេខ **E96/7** ត្រង់កថាខណ្ឌទី២១។

[24] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Ramush Haradinaj' និងគូរកន*, សំណុំរឿងលេខ IT-04-84*bis*-PT, សេចក្តីសំរេចលើញត្តិរបស់សហព្រះរាជអាជ្ញាដែលស្នើសុំ ឲ្យទទួលយកប្រតិចារិកនៃភស្តុតាង ជាជំនួសឲ្យការធ្វើសក្ខីកម្មដោយផ្ទាល់មាត់អនុលោមតាមវិធាន៩២*ស្ទួន* (អង្គជំនុំជម្រះសាលាដំបូងទីIIនៃតុលាការ ICTY), ចុះថ្ងៃទី២២ កក្កដា ២០១១ , ត្រងកថាខណ្ឌពីទី ១៩-២១។

[25] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Stanislav Galić*, សំណុំរឿងលេខ IT-98-29-AR73.2, សេចក្តីសម្រេចលើបណ្តឹឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំទាក់ទងនឹងវិធាន៩២*ស្ទួន*(គ) (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី៧ មិថុនា ២០០២ ត្រង់កថាខណ្ឌទី១១។ សង្កត់ន័យដោយអក្សរទ្រេតនៅក្នុងច្បាប់ដើម។

សួរដេញដោលសាក្សីដោយផ្ទាល់មាត់ ដើម្បីគោលបំណងចង់បង្ហាញភ័ស្តុតាងអំពីអំពើ និងការប្រព្រឹត្តិនានារបស់ជនជាប់ចោទនោះឡើយ។ បើសិនជានៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឬសក្ខីកម្មសាក្សីណាមួយដែលរួមបញ្ចូលភ័ស្តុតាង នោះសហព្រះរាជអាជ្ញាគ្រាន់តែដាក់ជូនតែឯកសារណាដែលសម្រាប់គោលបំណងបង្ហាញសក្ខីកម្មពីបញ្ហាផ្សេងៗទៀត ដែលអង្គជំនុំជម្រះបានអនុញ្ញាតហើយតែប៉ុណ្ណោះ ដូចជាអំពីបរិបទស្តីពីគោលនយោបាយឧក្រិដ្ឋនានា, រចនាសម្ព័ន្ធផ្នែករដ្ឋបាល និងការប្រាស្រ័យទាក់ទង, បរិបទខាងប្រវត្តិសាស្ត្រ នយោបាយ និងយោធារបស់កម្ពុជាប្រជាធិបតេយ្យ លក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនៃការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល និងជម្លោះប្រដាប់អាវុធដូចដែលបានកំណត់អត្តសញ្ញាណយ៉ាងជាក់លាក់ នៅក្នុងកថាខណ្ឌទី៩ នៃសំណើនេះ។ ឯកសារដែលបានទាមទារសុំដើម្បីឲ្យទទួលយកនេះ ត្រូវបានបង្ហាញអត្តសញ្ញាណពេញលេញទាំងស្រុងនៅក្នុង**ឧបសម្ពន្ធទី១ និងទី២** ហើយជាងនេះទៅទៀត មានការបង្ហាញអត្តសញ្ញាណបន្ថែមទៀតនៅក្នុងទម្រង់សម្រាប់វិភាគដែលមាននៅក្នុង**ឧបសម្ព័ន្ធចាប់ពីទី៣** ដល់**ទី១៦**។ ដើម្បីជាជំនួយដល់អង្គជំនុំជម្រះ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឬសក្ខីកម្មសាក្សីដែលរួមបញ្ចូលនូវភ័ស្តុតាងមួយចំនួននៅក្នុងនោះ អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទនៅក្នុងចំណោមបញ្ហាដទៃៗជាច្រើនទៀត ត្រូវបានបង្ហាញអត្តសញ្ញាណនៅក្នុងទម្រង់វែងដែលមាននៅក្នុង**ឧបសម្ព័ន្ធទី១ និងទី២** “ចំណុចនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ” និងនៅក្នុងទម្រង់ខ្លី នៅក្នុង**ឧបសម្ព័ន្ធទី៣** ដល់**ទី១៦** គឺ “**[a&c]**”ដែលមានន័យថា [អំពើ និងការប្រព្រឹត្ត]។

## ខ. ឯកសារនាំឲ្យឃើញដែលទាក់ទងទៅនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មនានាទៅលើជនរងគ្រោះ

១៨- សេចក្តីសម្រេចរបស់អង្គជំនុំជម្រះបានរៀបចំជាបញ្ជីយ៉ាងជាក់លាក់ស្តីពី “ផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ”ធ្វើជាកត្តាដែលគាំទ្រចំពោះការទទួលយក និងការកំណត់ទម្ងន់ទៅលើភ័ស្តុតាង[26]។ ការប្តេជ្ញាចិត្តនេះត្រូវបានចែងនៅក្នុងបុព្វកថានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជ

---

[26] **E96/7** សេចក្តីសម្រេច ត្រង់កថាខណ្ឌទី២៤(ឃ)។

រដ្ឋាភិបាលកម្ពុជា ដែលបានប្រកាសថាជាគោលដៅរបស់ខ្លួនក្នុងការ “ស្វែងរកយុត្តិធម៌ និងការបង្រួបបង្រួមជាតិ”[27]។

១៩- ឯកសារភាគច្រើន ដែលបង្ហាញអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មនានាទៅលើជនរងគ្រោះក្នុងនោះ គឺមានកត្តាមួយផ្សេងទៀតដែលគាំទ្រឲ្យទទួលយកនោះ គឺដោយសារថា ឯកសារទាំងនោះបានផ្តល់នូវភ័ស្តុតាងដែលស៊ីសង្វាក់គ្នាស្តីពីលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនៃការវាយប្រហារទៅលើប្រជាជនស៊ីវិល និងបង្ហាញសក្ខីកម្មអំពីគោលនយោបាយឧក្រិដ្ឋរបស់បក្សកម្មុយនីស្តកម្ពុជា នៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ។ ទោះជាយ៉ាងណាក្តី ដោយហេតុថា ការចូលរួមរបស់ជនរងគ្រោះ គឺជាទិដ្ឋភាពជាក់ស្តែងដ៏សំខាន់មួយរបស់ អវតក ការទទួលស្គាល់អំពីផលប៉ះពាល់នៃបទឧក្រិដ្ឋទៅលើជនរងគ្រោះម្នាក់ៗ គឺមិនគ្រាន់តែជាកិច្ចដំណើរការនៃការផ្សះផ្សាជាតិជាសារវន្តដែលតុលាការនេះ ត្រូវបានគេរៀបចំបង្កើតដើម្បីជម្រុញឲ្យប្រសើរឡើងប៉ុណ្ណោះទេ ក៏ប៉ុន្តែដើម្បីផ្តល់ជាឧទាហរណ៍ជាក់ស្តែង អំពីការខូចខាតដែលបានបង្កឡើង[28]។

## គ. ឯកសារទាំងឡាយត្រូវតែគួរឲ្យជឿទុកចិត្តបាន

២០- អង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងផ្នែកទី៤(៣) នៃសេចក្តីសម្រេចដែលទាំងភាពអាចទទួលយកបាន និងទាំងទម្ងន់នៃភ័ស្តុតាងនៅក្នុងសេចក្តីសន្និដ្ឋាននេះ គឺសុទ្ធតែពឹងផ្អែកទៅលើភាពគួរឲ្យជឿទុកចិត្តបាន

[27] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់ នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ៦ មិថុនា ២០០៣ ត្រង់ទំព័រទី១។

[28] នៅក្នុងពាក្យបណ្តឹងនានារបស់ជនរងគ្រោះ មានការលើកឡើងជាដដែលៗអំពីការសម្រេចឲ្យបាននូវយុត្តិធម៌សំរាប់ការបាត់បង់នូវសមាជិកគ្រួសារ និងជនរងគ្រោះដទៃទៀតនៅក្នុងទូទាំងប្រទេស តាមរយៈការដាក់ពាក្យបណ្តឹងជូន អវតក (*សូមអាន* ឧទាហរណ៍ដូចជាទម្រង់នៃពាក្យបណ្តឹងរបស់ឈ្មោះ ជូ គឹមឡាន (CHOU Kim Lan), ឯកសារលេខ D230/2/4.2.138a, ទម្រង់សម្រាប់ពត៏មានបន្ថែមទាក់ទងនឹងការផ្លាស់ប្តូរឋានៈពីដើមបណ្តឹងរដ្ឋប្បវេណី ទៅជា អ្នកប្តឹង)។ គួរបានធ្វើការកត់សម្គាល់ទៅលើមាត្រា៦៨(៣)នៃលក្ខន្តិកៈនៃទីក្រុងរ៉ូម របស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានចែងថា៖ “នៅពេលដែលផលប្រយោជន៍ឯកជនរបស់ជនរងគ្រោះត្រូវទទួលរងនូវផលប៉ះពាល់នោះ តុលាការត្រូវអនុញ្ញាតឲ្យធ្វើការលើកឡើងបង្ហាញអំពីទស្សនៈនិងការព្រួយបារម្ភរបស់ពួកគេ ហើយពិនិត្យពិចារណាទៅតាមដំណាក់កាលនៃដំណើរការនីតិវិធីតាមការយល់ឃើញរបស់តុលាការថា សមស្របនិងក្នុងលក្ខណៈមិនឲ្យមានការប៉ះពាល់ដល់ ឬមិនស្របទៅនឹង សិទ្ធិរបស់ជនជាប់ចោទ ហើយទៅនឹងគោលការណ៍នៃការជំនុំជម្រះក្តីដោយត្រឹមត្រូវ និងមិនលំអៀង ”។ ទស្សនៈនិងការព្រួយបារម្ភទាំងនោះអាចត្រូវបានបង្ហាញជូនដោយមេធាវីតំណាងរបស់ជនរងគ្រោះបើសិនជាតុលាការយល់ឃើញថា ជាការសមស្របដោយអនុលោមតាមវិធានស្តីពីនីតិវិធី និងភស្តុតាង។

នៃប្រភពដើមរបស់ឯកសារនិមួយៗ[29]។ ប្រភេទផ្សេងៗនៃឯកសារពាក់ព័ន្ធនានាត្រូវបានលើកយកមកធ្វើការវិភាគដូចខាងក្រោមនេះ៖

*i. ប្រតិចារឹកនានានៃសំណុំរឿងលេខ០០១*

២១- អង្គជំនុំជម្រះបានសម្រេចថា នៅក្នុងប្រតិចារឹកទាំងឡាយមកពីសំណុំរឿងលេខ០០១ គឺមានសញ្ញាបង្ហាញដែលជាប់មកជាមួយស្រាប់ស្តីពីភាពគួរឲ្យជឿទុកចិត្តបាន ពីព្រោះសាក្សីនានាបាននិយាយនៅក្នុងតុលាការព្រហ្មទណ្ឌក្រោយពីការធ្វើសម្បថរួច។ ទោះជាយ៉ាងណា អង្គជំនុំជម្រះបានអនុញ្ញាត ក្នុងកាលៈទេសៈមួយចំនួនឲ្យប្រើប្រាស់នូវប្រតិចារឹកនានាដែលបានមកពីសវនាការជំនុំជម្រះក្តី កាលពីលើកមុន ដើម្បីបង្ហាញសក្ខីកម្មអំពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ[30]។ ដូចដែលប្រតិចារឹកដែលភ្ជាប់ជាឧបសម្ព័ន្ធជាមួយនឹងញត្តិនេះ គឺមានគោលបំណងចង់ឲ្យមានភាពស៊ីសង្វាក់គ្នាលើបញ្ហានានាដែលមិនជាប់ទាក់ទងទៅនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ប្រតិចារឹកនេះកំណត់ជាចំបងអំពីគោលនយោបាយព្រហ្មទណ្ឌ និងទម្រង់ជាទូទៅនានានៃអំពើឧក្រិដ្ឋ - **អាចឲ្យទទួលយកបានតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ**[31]។ ក្នុងចំណោមប្រតិចារឹកនៃសក្ខីកម្មនាពេលសវនាការទាំង ៤០ ដែលបានស្នើឲ្យទទួលយក ទាំងអស់សុទ្ធតែមានជាបីភាសាការងាររបស់ អវតក រួចហើយ។

*ii. កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ កសចស*

២២- អង្គជំនុំជម្រះបានសម្រេចថា "ចម្លើយទាំងឡាយដែលស្រង់បាននៅក្នុងអម្តុងពេលនៃកិច្ចស៊ើបសួរ គឺមានភាពជាប់ទាក់ទង និងអំពីភាពគួរឲ្យជឿទុកចិត្តបានក្នុងការសន្និត"[32]។ នៅពេលដែលចម្លើយទាំងនោះមិនមែនជាកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមានពាក្យពេចន៍ដូចគ្នាគ្រប់ម៉ាត់ ឯកសារ

[29] **E96/7** សេចក្តីសម្រេច ត្រង់កថាខណ្ឌទី២៦-៣៣។

[30] **E96/7** សេចក្តីសម្រេច ត្រង់ទំព័រទី៣០-៣១។

[31] **E96/7** សេចក្តីសម្រេច ត្រង់ទំព័រទី៣០។

[32] **E96/7** សេចក្តីសម្រេច ត្រង់ទំព័រទី២៦។

នានាដែលកត់ត្រានូវចម្លើយទាំងនោះដែលត្រូវបានធ្វើឡើងក្រោមការស្បថ អនុលោមតាមវិធាន២៤ សម្រាប់ អ.វ.ត.ក និងថាទម្រង់សង្ខេបនៃការស្តាប់ចម្លើយនោះត្រូវបានអានដោយសាក្សី ឬអានឡើងវិញឲ្យសាក្សីស្តាប់ ហើយត្រូវបានទទួលយល់ព្រម និងចុះហត្ថលេខាថាជាការរៀបរាប់រឿងរ៉ាវមួយប្រកបដោយការពិតអំពីការសម្ភាសន៍។ ដើម្បីធានាឲ្យប្រាកដអំពីភាពគួរឲ្យជឿទុកចិត្តបានចម្លើយដែលបានចុះហត្ថលេខារួចនេះមានអមដោយខ្សែអាត់ថតសម្លេងមួយចំនួន[33]។ ភាពត្រឹមត្រូវនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរដែលច្របាច់បញ្ចូលគ្នាទាំងនេះ ត្រូវបានបញ្ជាក់បន្ថែមទៀតដោយសាក្សីជាច្រើនទៀតដែលផ្តល់សក្ខីកម្មអំពីការពិតនៃចម្លើយរបស់ពួកគេ។ មិនមានសាក្សីណាម្នាក់បានតវ៉ាថាចម្លើយដែលពួកគេបានផ្តល់ឲ្យមន្ត្រីស៊ើបអង្កេតរបស់ កសចស ត្រូវបានធ្វើឡើងដោយមានការបញ្ចុះបញ្ចូល ឬការបង្ខិតបង្ខំណាមួយនោះឡើយ[34]។ នៅក្នុងចំណោមកំណត់ហេតុទាំង៥២៦ដែលបានស្នើឡើងដើម្បីឲ្យយល់ព្រមទទួលយកសុទ្ធតែមានស្រាប់ដែលអាចងាយរកបាន ជាបីភាសានៃភាសាការងាររបស់ អវតក ដែលមានមួយបកប្រែជាភាសាខ្មែរ និងបួនបកប្រែជាភាសាបារាំង[35]។

*iii. កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានធ្វើឡើងដោយស្ថាប័នខាងក្រៅ អ.វ.ត.ក (កសចស)*

២៣- **ឧបសម្ព័ន្ធ** ១ មានកំណត់ហេតុដែលទទួលបានពីប្រភពនានាក្រៅពី អ.វ.ត.ក ហើយក៏មានពាក្យបណ្តឹងដែលបានសរសេរឡើងក្នុងគោលបំណងដាក់មក អ.វ.ត.ក។ អង្គជំនុំជម្រះបានសម្រេចបន្ថែមទៀតថា កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមិនបានកោះហៅមកផ្តល់ភស្តុតាងនៅពេលសវនាការ ដែលបានធ្វើឡើងដោយស្ថាប័នខាងក្រៅ អ.វ.ត.ក ទោះបីជាកំណត់ហេតុទាំងនោះមិនដូចកំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេត និងប្រតិចារឹកសវនាការក៏ដោយ ក៏កំណត់ហេតុនិងប្រតិចារឹកទាំងនោះមិនមានផ្ទុកនូវសច្ចធារណ៍នៃភាពជឿទុកចិត្តបានដែរ។ ប៉ុន្តែ តុលាការដទៃទៀតក៏បានទទួលយកជាភស្តុតាងនូវកំណត់ហេតុដែលបានធ្វើឡើងដោយអាជ្ញាធរ ដែលមិនមែនជា

---

[33] **E96** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ទាក់ទងនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ១៥ មិថុនា ២០១១ ត្រង់កថាខណ្ឌទី៣៨ (“សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា”)។

[34] *សូមអាន* **E96** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ត្រង់កថាខណ្ឌទី១៤។

[35] បុគ្គលភាគច្រើនដែលបានចុះបញ្ជីនៅក្នុងឧបសម្ព័ន្ធនានា បានដាក់ទៅក្នុងបញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០ ប៉ុន្តែមិនទាន់បានកោះហៅមកធ្វើសក្ខីកម្មនៅឡើយដោយអង្គជំនុំជម្រះសាលាដំបូង។ *សូមអាន* **E9/4.1** ឧបសម្ព័ន្ធ ភ្ជាប់ជាមួយនឹងបញ្ជីសាក្សីអ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០, ២៨ មករា ២០១១។

អ្នកស៊ើបអង្កេតរបស់តុលាការ[36]។ ជាឧទាហរណ៍ នៅក្នុងករណី *Perišić* អង្គជំនុំជម្រះសាលាដំបូងបានទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីជាច្រើន ដែលរៀបរាប់ពីការបាញ់ផ្លោង ទៅលើតំបន់នានារបស់ជនស៊ីវិលដែលទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្ម សូម្បីតែកំណត់ហេតុស្តាប់ចម្លើយទាំងនោះត្រូវបានធ្វើឡើងចំពោះអាជ្ញាធរស៊ីវិលនៃប្រទេស Boznia និង Herzegovina ក៏ដូចជាធ្វើឡើងចំពោះការស៊ើបអង្កេតចោទប្រកាន់ផងដែរ។ អង្គជំនុំជម្រះនេះក៏បានទទួលស្គាល់ផងដែរថា ឯកសារមួយអាចមានសូចនាររបស់វាអំពីភាពជឿទុកចិត្តបាន មានដូចជាការដឹងអំពីប្រភពនៃឯកសារ ភាពស៊ីសង្វាក់គ្នា កម្រិតនៃភាពពិស្តារ និងកម្រិតដែលឯកសារនោះអះអាងបញ្ជាក់អង្គហេតុផ្សេងៗទទួលបានពីកន្លែងផ្សេង[37]។

## <u>ពាក្យបណ្តឹងរបស់ជនរងគ្រោះ</u>

២៤- នៅខណៈដែលពាក្យបណ្តឹងរបស់ជនរងគ្រោះ មានកង្វះខាតនូវការអនុម័តយល់ព្រមជាផ្លូវការ ជាកំណត់ហេតុ កសចស[38] អង្គជំនុំជម្រះសាលាដំបូងអាចវាយតម្លៃអំពីតម្លៃភវនីយភាពនៃពាក្យបណ្តឹងដូច្នេះបាន ដោយឈរលើមូលដ្ឋាន ថាតើពាក្យបណ្តឹងទាំងនោះអះអាងបញ្ជាក់ពីភ័ស្តុតាងដទៃទៀតឲ្យជឿទុកចិត្តបានជាងដោយរបៀបណា។ សាលាក្តីនេះ លើកទឹកចិត្តឲ្យមានការចូលរួមរបស់ជនរងគ្រោះ តាមរយៈវិធាន១២*ស្ទួន*(១)(ក) តាមរយៈការដាក់ពាក្យបណ្តឹង ហើយក្រៅអំពីការដាក់ពាក្យបណ្តឹងដូច្នេះ គេគ្មានមធ្យោបាយណាផ្សេងដែលជនរងគ្រោះមិនមែនជាភាគីដើមបណ្តឹងអាចចូលរួមបាននៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ។ ដូចដែលសាលាក្តីនេះមានបំណងធ្វើជាតុលាការមួយសម្រាប់

---

[36] *រដ្ឋអាជ្ញា ទល់នឹង Momčilo Perišić*, IT-04-81-T, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា ស្នើសុំឲ្យទទួលយកភ័ស្តុតាង ដោយអនុលោមតាមវិធាន៩២*ស្ទួន* (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY), ២ តុលា ២០០៨ ត្រង់កថាខណ្ឌទី២០-៣៣។

[37] សូមអាន ឯកសារ **E158** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន៩២ ទាក់ទិននឹងសូចនាបង្ហាញអំពីភាពជឿទុកចិត្តចំពោះឯកសារចំនួន៩៧៨ ដែលបានដាក់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅសម្រាប់សវនាការបីសប្តាហ៍ដំបូង, ២៣ ធ្នូ ២០១១។

[38] បុគ្គលនានាដែលបានជួយក្នុងការសរសេរ និងដាក់ជូននូវពាក្យបណ្តឹងដោយអង្គភាពគាំពារជនរងគ្រោះនៃ អ.វ.ត.ក ព្រមទាំងបានអនុម័តលើសមាគមជនរងគ្រោះ ស្របតាមវិធាន២៣*ស្ទួន*។ ជាងនេះទៀត ពាក្យបណ្តឹងដើម (ជាភាសាខ្មែរ) ដែលបានដាក់តាមរយៈទម្រង់របស់ VSS ដែលមានផ្ទុកនូវព័ត៌មានអំពីអ្នកប្តឹង និងការរៀបរាប់អំពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ ត្រូវបានចុះហត្ថលេខា ឬផ្តិតមេដៃនៅលើគ្រប់ទំព័រដោយជនរងគ្រោះ។ ទម្រង់បែបបទនេះក៏តម្រូវឲ្យអ្នកប្តឹងម្នាក់ៗចុះហត្ថលេខា ឬផ្តិតម្រាមដៃផងដែរ ដើម្បីទុកជាការធានាអះអាងថា តាមការយល់ដឹង និងជំនឿពិតប្រាកដរបស់ពួកគាត់ ព័ត៌មានដែលបានផ្តល់ជូនក្នុងទម្រង់បែបបទ គឺពិតជាត្រឹមត្រូវ និងថា បើមិនដូច្នេះទេ បុគ្គលនោះនឹងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ ហេតុដូច្នេះ ច្បាស់ណាស់ថា អ្នកដាក់ពាក្យបណ្តឹងបានដឹងអំពីលក្ខណៈនៃកំណត់ហេតុរបស់ខ្លួនដែលថាពិតជាមានរឿងរ៉ាវដ៏សំខាន់ខាងអង្គហេតុ និងអំពីគោលបំណងសម្រាប់ព័ត៌មានទាំងនោះដែលនឹងត្រូវគេយកទៅប្រើប្រាស់។

ប្រជាជនកម្ពុជាគ្រប់រូប គឺជាបន្ទុកដ៏ធ្ងន់ចំពោះសាលាក្តីនេះក្នុងការទទួលយល់ព្រម និងទទួលស្គាល់លើពាក្យបណ្តឹងនានា ទុកដូចជាការរួមចំណែកដល់មុខងារសវនាការនៅក្នុងការស្វែងរកការពិត តាមរយៈការទទួលយកពាក្យបណ្តឹងទាំងនោះ ជាភស្តុតាងសម្រាប់បញ្ជាក់អះអាង តាមវិធាន៨៧(៣)។ ក្នុងចំណោមពាក្យបណ្តឹងចំនួន៤១០ (ជាភាសាខ្មែរ) ដែលបានស្នើសុំឲ្យទទួលយក មានពាក្យបណ្តឹងចំនួន២៧ ដែលត្រូវឲ្យបកប្រែទៅជាភាសាអង់គ្លេស និង៣៩៦ ទៅជាភាសាបារាំង[39]។

២៥- មានការសន្និដ្ឋានថា ពេលវេលា និងការចំណាយលើការបកប្រែនៃពាក្យបណ្តឹងទាំងនេះ គឺតិចតួចទេ ព្រោះវាខ្លី។ ពាក្យបណ្តឹងជាមធ្យមមានចំនួន៧ទំព័រ ដែលនៅក្នុងនោះជាមធ្យមមានតែមួយទំព័រប៉ុណ្ណោះ ដែលមានការរៀបរាប់ពិតប្រាកដអំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ - គឺផ្នែកនេះដែលតម្រូវឲ្យបកប្រែ។ អត្ថប្រយោជន៍នៃការគិតគូរចំពោះពាក្យបណ្តឹងរបស់ប្រជាជនកម្ពុជានៅ អ.វ.ត.ក គឺផ្តល់ការអនុញ្ញាតឲ្យទទួលយកឯកសារទាំងអស់នេះ។

<u>កំណត់ហេតុដទៃទៀត</u>

២៦- កំណត់ហេតុដទៃទៀតដែលមាននៅក្នុង **ឧបសម្ព័ន្ធ ១** ត្រូវបានធ្វើឡើងដោយ (១) មជ្ឈមណ្ឌលឯកសារកម្ពុជា (“DC-Cam”), (២) ការិយាល័យសហព្រះរាជអាជ្ញា (“កសព”) និង(៣) សាលាសម្រាប់ការសិក្សាចុងបូព៌ា និងអាហ្វ្រិក **(the School for Oriental and African Studies) (“SOAS”)** ក្នុងចំណោមប្រភពផ្សេងទៀត។ ភាពជឿទុកចិត្តបានលើកំណត់ហេតុទាំងនេះ តម្រូវឲ្យមានការពិចារណាទាំងទៅលើភាពជឿទុកចិត្តបាននៃប្រភព និងភាពជឿទុកចិត្តបាននៃខ្លឹមសារ។ អង្គជំនុំជម្រះបានឲ្យដឹងថា ឯកសារដែលស្ថិតនៅមជ្ឈមណ្ឌល DC-Cam អាចត្រូវបានពិចារណាថាគួរឲ្យទុកចិត្តបានផងដែរ ដោយហេតុថាទម្លាប់នៃការអនុវត្តខាងបណ្ណសាររបស់វា ត្រូវបានក្លាយជាកម្មវត្ថុនៃការសួរដេញដោលដោយភាគី[40]។ កំណត់ហេតុជាក់លាក់ខ្លះ ត្រូវបានធ្វើកំណត់ត្រាដោយអ្នកស៊ើបអង្កេតដែលបំរើការងារឲ្យ កសព ហើយទោះបីជា កសព មិនបានទាមទារថាមានភាព

[39] ការបកប្រែជាភាសាអង់គ្លេសគឺជាទម្រង់សង្ខេប។ ការបកប្រែបានសង្ខេបលើការរៀបរាប់ជាក់ស្តែងនៃឧក្រិដ្ឋកម្មដែលបានលើកឡើងចោទប្រកាន់នៅក្នុងបណ្តឹង។ គេបានដាក់វាជូនថាការណ៍នេះគ្រប់គ្រាន់សម្រាប់គោលបំណងនៃការផ្តល់ជូនការស៊ើសង្ខាក់គ្នា។

[40] **E96/7** សេចក្តីសម្រេច ត្រង់កថាខណ្ឌទី២៩។

អព្យាក្រឹតដូចគ្នានឹង កសចស ក៏ដោយ ក៏កំណត់ហេតុដែលខ្លួនបានកត់ត្រាមានអង្គសេចក្ដីសម្រាប់ការទទួលយកនៅក្នុងបរិបទនៃការដាក់សេចក្ដីសន្និដ្ឋាននេះ។

២៧- នៅពេលមានសាក្សីណាម្នាក់បានធ្វើកំណត់ហេតុច្រើន កំណត់ហេតុទាំងនោះគួរតែត្រូវបានអានរួមគ្នាដើម្បីកំណត់អំពីភាពជឿទុកចិត្តបាន ជាពិសេសនៅពេលដែលកំណត់ហេតុខ្លះត្រូវបានផ្ដល់ជូនស្ថាប័នដែលគេអាចសន្មតបានថាគួរឱ្យជឿទុកចិត្តបាន មានដូចជា កសចស ជាដើម។ នៅខណៈដែលកំណត់ហេតុ និងពាក្យបណ្ដឹងបន្ថែមទាំងនេះ មិនមានផ្ទុកនូវសច្ចធារណ៍នៃភាពជឿទុកចិត្តបានដូចកំណត់ហេតុរបស់ កសចស ក៏ដោយ តែកំណត់ហេតុ និងពាក្យបណ្ដឹងទាំងនេះមានជាប់ទាក់ទងទៅនឹងអង្គហេតុដូចគ្នាដែលមាននៅក្នុងនោះ និងថាអាស្រ័យហេតុនេះ វានឹងធ្វើឱ្យកាន់តែមានភាពប្រសើរឡើងចំពោះភាពជឿទុកចិត្តបានអំពីកំណត់ហេតុទាំងនោះ នៅពេលណាមានការអានរួមគ្នា។ សហព្រះរាជអាជ្ញាសូមស្នើថា អង្គជំនុំជម្រះថ្លឹងថ្លែងលើភាពជឿទុកចិត្តបាននៃកំណត់ហេតុទាំងនេះទៅតាមមូលដ្ឋាននៃកំណត់ហេតុនិមួយៗរបស់វា ដោយការពិចារណាថាតើខ្លឹមសារនៃកំណត់ហេតុនោះស្របទៅនឹងអង្គហេតុដែលបានកំណត់ដែរ ឬអត់។

២៨- ក្នុងចំណោមកំណត់ហេតុ៤២០ផ្សេងទៀត (មិនរាប់បញ្ចូលពាក្យបណ្ដឹង) ដែលបានស្នើឱ្យទទួលយកគឺការបកប្រែភាគច្រើនបានបញ្ចប់ហើយ។ ការបកប្រែនៅសល់មានតែ៤២សម្រាប់ភាសាខ្មែរ ១៦សម្រាប់ភាសាអង់គ្លេស និង១២៣ សម្រាប់ភាសាបារាំង ប៉ុណ្ណោះដែលត្រូវបកប្រែ។ ហេតុដូចនេះដរាបណាភាពពាក់ព័ន្ធ និងភាពជឿទុកចិត្តបានត្រូវបានកំណត់ បញ្ហានៃការចំណាយ និងពេលវេលាសម្រាប់ការបកប្រែកំណត់ហេតុទាំងនេះ គឺតិចតួច។

## ឃ. ការពិចារណាផ្សេងទៀត

២៩- នៅក្នុងការស្នើសុំឱ្យទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងសក្ខីកម្មពេលសវនាការធ្វើជាភស្តុតាងសម្រាប់បញ្ជាក់អះអាង អង្គជំនុំជម្រះបានបង្គាប់ឱ្យភាគី "ពិចារណាក្នុងការស្នើសុំដាក់នៅចំពោះមុខខ្លួន នូវគំរូបង្ហាញនៃប្រភេទភស្តុតាងនិមួយៗ" បើសិនជាភស្តុតាងនោះច្រើន ឬមានលក្ខណៈជាន់គ្នាជាសំខាន់"[41]។ សេចក្ដីណែនាំនេះត្រូវបានធ្វើឡើង "ក្នុងទស្សនៈតម្រូវការក្នុងការបក

[41] E96/7 សេចក្ដីសម្រេច ត្រង់កថាខណ្ឌទី៣៥។

ប្រែចំនួនដ៏ច្រើននៃសម្ភារៈឯកសារ ដូចគ្នានឹងពេលវេលាជាសក្តានុពល ឬជាសារធាតុនៅក្នុងតុលាការដែលត្រូវបែងចែកសម្រាប់ការស្តាប់ការជំទាស់ទៅនឹងសម្ភារៈឯកសារទាំងនោះ”[42]។ ទន្ទឹមនេះ សហព្រះរាជអាជ្ញាបានយកចិត្តទុកដាក់ទៅលើសេចក្តីពិចារណានេះ ស្របតាមស្មារតីនៃលក្ខខណ្ឌតម្រូវរួមដែលថា សវនាការកាត់ក្តីនេះ “ត្រឹមត្រូវយុត្តិធម៌ និងឆាប់រហ័ស”[43] និងតាមស្មារតីនៃកត្តាផ្សេងៗទៀតដូចបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង។

## ភាពត្រឹមត្រូវយុត្តិធម៌

៣០- ដើម្បីធានាឲ្យប្រាកដថា សវនាការមានលក្ខណៈត្រឹមត្រូវយុត្តិធម៌ចំពោះជនជាប់ចោទ សហព្រះរាជអាជ្ញាត្រូវតែកំណត់ឲ្យបានហួសពីវិមតិសង្ស័យ មិនត្រឹមតែបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធាតុផ្សំខាងយុត្តាធិការនៃបទឧក្រិដ្ឋផងដែរ។ ដើម្បីបំពេញឲ្យបាននូវបន្ទុកនេះ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សហព្រះរាជអាជ្ញាត្រូវតែបញ្ជាក់ភ័ស្តុតាងឲ្យបានថា ឧក្រិដ្ឋកម្មទាំងនេះគឺជាផ្នែកនៃការវាយប្រហារទូលំទូលាយ និងជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល។ ដូចគ្នានេះ សហព្រះរាជអាជ្ញាត្រូវតែកំណត់ឲ្យបាននូវរចនាសម្ព័ន្ធរដ្ឋបាល ការប្រាស្រ័យទំនាក់ទំនង និងឃោធារបស់កម្ពុជាប្រជាធិបតេយ្យ គោលនយោបាយនានាដែលគាំទ្រដល់របបនេះ និងអត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួម។ អាស្រ័យដោយចំនួននៃសក្ខីកម្មផ្ទាល់មាត់ដែលតុលាការអាចនឹងមានលទ្ធភាពស្តាប់ និងដោយការពិចារណាលើភាពចាំបាច់នៃការកំណត់ពីអត្ថិភាពនៃឧក្រិដ្ឋកម្មឲ្យបានត្រឹមត្រូវដើម្បីបង្ហាញអំពីអត្ថិភាពឧក្រិដ្ឋកម្ម ករណីពាក់ព័ន្ធនឹងសហកម្មឧក្រិដ្ឋកម្មរួមក្នុងទំហំមួយដ៏ធំ និងការអនុវត្តគោលនយោបាយឧក្រិដ្ឋនានាជាញឹកញាប់ ត្រូវប្រើភ័ស្តុតាងប្រយោលដើម្បីផ្តល់លទ្ធភាពឲ្យចៅក្រមអាចទាញសេចក្តីសន្និដ្ឋានបាន អំពីអត្ថិភាពនៃគោលនយោបាយ រចនាសម្ព័ន្ធ និងការវាយប្រហារដូច្នេះ។

[42] **E96/7** សេចក្តីសម្រេច ត្រង់កថាខណ្ឌទី៣៥។

[43] មាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានដាក់បញ្ចូលវិសោធនកម្ម ដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

៣១- សារៈសំខាន់នៃការប្រើប្រាស់ភ័ស្តុតាងប្រយោល គឺបានបង្ហាញយ៉ាងច្បាស់នៅក្នុងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត។ ក្នុងរឿងក្តី *រដ្ឋអាជ្ញាទល់នឹង Milutinovic* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចថា រដ្ឋអាជ្ញាមិនតម្រូវឲ្យបង្ហាញ "ភ័ស្តុតាងច្បាស់លាស់" ទាក់ទងនឹង JCE ដោយហេតុថា "អង្គជំនុំជម្រះអាចទាញសេចក្តីសន្និដ្ឋានថា គោលបំណង ឬផែនការរួមដែលបានកើតឡើងតាមការពិនិត្យទៅលើកាលៈទេសៈទាំងមូល ជុំវិញការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបទល្មើសជាដើមចម"[44]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា "មធ្យោបាយដែលឧក្រិដ្ឋកម្ម ឬបទល្មើសជាដើមអាទិ៍ត្រូវបានប្រព្រឹត្តឡើង អាចគាំទ្រដល់ការទាញសេចក្តីសន្និដ្ឋានមួយដែលត្រូវតែអនុលោមតាមផែនការរួម"[45]។ ស្រដៀងគ្នានេះ ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galic*, អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា គេអាចអនុញ្ញាតឲ្យមានការទាញសេចក្តីសន្និដ្ឋាន "ការបញ្ជា" ដោយផ្អែកលើកត្តាផ្សេងៗដូចជា "ចំនួននៃអំពើខុសច្បាប់, ចំនួន អត្តសញ្ញាណ និងប្រភេទនៃកងកម្លាំងដែលពាក់ព័ន្ធ, ការបញ្ជា និងការត្រួតត្រាដោយប្រសិទ្ធភាពដែលបានដាក់ទៅលើកងកម្លាំងទាំងនោះ កិច្ចការភ័ស្តុភារដែលពាក់ព័ន្ធ ការកើតឡើងរីករាលដាលនៃអំពើខុសច្បាប់ទាំងនេះ ចង្វាក់នៃកលយុទ្ធនៃប្រតិបត្តិការ វិធីអនុវត្តចំពោះអំពើស្រដៀងគ្នានេះ..."[46]។ ជាថ្មីម្តងទៀត ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krstic*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៅក្នុងការសួរដេញដោលពីកងកម្លាំង VRS (កងទ័ពស៊ែប៊ូស្នី-Bosnian Serb Army) ដែលបានធ្វើការផ្លាស់ប្តូរទីលំនៅជនស៊ីវិលអ៊ីស្លាមប៊ូស្នី ដោយអនុលោមតាមគោលដៅនៃអំពើប្រល័យពូជសាសន៍ បានរកឃើញថា "ចេតនាប្រល័យពូជសាសន៍" អាចត្រូវបានគេទាញសេចក្តីសន្និដ្ឋានពីភ័ស្តុតាងនៃអំពើដែលស្ថិតនៅក្រោមការទទួលខុសត្រូវដទៃទៀត ដែលសំដៅជាប្រព័ន្ធប្រឆាំងក្រុមដូចគ្នា នៅក្នុងចំណោមអង្គហេតុដទៃទៀត"[47]។

៣២- នៅក្នុងការវាយតម្លៃអំពីភ័ស្តុតាងដែលស៊ីសង្វាក់គ្នា តុលាការ ICTR បានយកវិធីសាស្ត្រស្រដៀងគ្នានេះដែរ។ ក្នុងករណី *រដ្ឋអាជ្ញា ទល់នឹង Mpambara* ដែលគ្មានភ័ស្តុតាងផ្ទាល់ស្តីពីការចូលរួម

---

[44] *រដ្ឋអាជ្ញា ទល់នឹង Milan Milutinovic និងគូកន,.*, សំណុំរឿងលេខ: IT-05-87-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ២៦ កុម្ភៈ ២០០៩ ត្រង់កថាខណ្ឌទី១០២។

[45] ដូចគ្នាខាងលើ

[46] *រដ្ឋអាជ្ញា ទល់នឹង Stanislav Galic*, សំណុំរឿងលេខ: IT-98-29-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ២ ធ្នូ ២០០៣ ត្រង់កថាខណ្ឌទី១៧១។

[47] *រដ្ឋអាជ្ញា ទល់នឹង Radislav Krstic*, សំណុំរឿងលេខ: IT-98-33-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ១៩ មេសា ២០០៤ ត្រង់កថាខណ្ឌទី៣៣។

ចំណែករបស់ជនជាប់ចោទនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យរដ្ឋអាជ្ញាលើកឡើងពី "ករណីប្រយោល" ដែលមាន "ភស្តុតាងស្តីពី កាលៈទេសៈផ្សេងៗគ្នាមួយចំនួន" ដែលរួមបញ្ចូលគ្នាទៅចង្អុលបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទ"[48]។ វិធីសាស្ត្ររបស់តុលាការនៅក្នុងករណី *Mpambara* បានឆ្លុះបញ្ចាំងពីទស្សនៈនៃការគ្រប់គ្រងរបស់តុលាការ ICTR ស្តីពីការទទួលយកភស្តុតាង។ ដូចដែលបានបញ្ជាក់នៅក្នុង ករណី *រដ្ឋអាជ្ញា ទល់នឹង* Gatete ដូច្នោះដែរ ដោយការពិចារណាពី "ទំហំនៃព្រឹត្តិការណ៍ តាមពេលវេលា និងទីកន្លែង" នៅក្នុងករណីនានាដែលនៅចំពោះមុខអង្គជំនុំជម្រះ ឧក្រិដ្ឋកម្មនានារបស់ជនជាប់ចោទដែលបានចោទប្រកាន់ គឺមិនមែនជា "បទល្មើសដាច់ដោយឡែកតែឯង" នោះទេ[49]។ ហេតុដូច្នេះ ការអនុញ្ញាតឲ្យមានសក្ខីកម្មសាក្សីអំពីព្រឹត្តិការណ៍នានា ដែលនៅក្រៅយុត្តាធិការពេលវេលារបស់តុលាការនោះ គឺអង្គជំនុំជម្រះបានថ្លែងថាខ្លួននឹង "មានលទ្ធភាពធ្វើការថ្លឹងថ្លែងភស្តុតាងបានត្រឹមត្រូវ" ទាំងស្រុង ខណៈដែលនៅសល់តែ "ការគិតពីកាតព្វកិច្ចរបស់ខ្លួនក្នុងការគោរពសិទ្ធិរបស់ជនជាប់ចោទ"[50]។ បទចោទនានា នៅក្នុងសំណុំរឿងលេខ០០២ គឺមានប្រទាក់ក្រឡាស្រដៀងគ្នានេះដែរ។

៣៣- ដោយការពិចារណាទៅលើតួនាទីនៃភស្តុតាងប្រយោល និងអត្ថន័យនៃពាក្យ "ហួសពីវិមតិសង្ស័យ" ដែលភស្តុតាងមានលក្ខណៈជាប្រយោលនោះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា៖

*ករណីប្រយោលមានភស្តុតាងស្តីពីកាលៈទេសៈផ្សេងៗគ្នាមួយចំនួនដែលរួមបញ្ចូលគ្នា ចង្អុលបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទ ពីព្រោះជាទូទៅវាមានអត្ថិភាព រួមជាមួយគ្នាពីព្រោះថាជនជាប់ចោទបានធ្វើនូវអ្វីដែលគេបានចោទប្រកាន់ប្រឆាំងនឹងគាត់...។ សេចក្តីសន្និដ្ឋានបែបដូច្នេះត្រូវតែបានបង្កើតឡើងឲ្យហួសពីវិមតិសង្ស័យ។ វាមិនគ្រប់គ្រាន់ទេដែលថា សេចក្តីសន្និដ្ឋានសមហេតុសមផលមួយអាចបានពីភស្តុតាងនោះ។ វាត្រូវតែមានសេចក្តីសន្និដ្ឋានសមហេតុសមផលមួយទៀត។ បើមានសេចក្តីសន្និដ្ឋានមួយផ្សេងទៀតដែល មានលក្ខណៈបើកចំហរ*

---

[48] *រដ្ឋអាជ្ញា ទល់នឹង Jean Mpambara,* សំណុំរឿងលេខ ICTR-01-65-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR), ថ្ងៃទី១១ កញ្ញា ២០០៦ ត្រង់កថាខណ្ឌទី៤២។

[49] *រដ្ឋអាជ្ញា ទល់នឹង Jean-Baptiste Gatete,* សំណុំរឿងលេខ ICTR-2000-61-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ស្តីពីការទទួលយកការលើកឡើងចោទប្រកាន់នៅខាងក្រៅយុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះ(អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR), ថ្ងៃទី០៣ វិច្ឆិកា ២០០៩ ត្រង់កថាខណ្ឌទី១៨។

[50] ករណី *Gatete,* ត្រង់កថាខណ្ឌទី១៩។

*សមហេតុសមផលផងដែរពីភស្តុតាងនោះ ហើយដែលត្រូវគ្នាទៅនឹងភាពស្លូតត្រង់របស់ជនជាប់ចោទនោះ គឺគាត់ត្រូវតែបានលើកលែងការចោទប្រកាន់*[51]។

៣៤- ភស្តុតាងប្រយោលដែលស៊ីសង្វាក់គ្នា ដែលបានទាញយកមកពីជនរងគ្រោះ និងសាក្សីនានា នៅទូទាំងប្រទេស គឺមិនគ្រាន់តែមានតម្លៃប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសារៈសំខាន់ទៀតផង ក្នុងការបង្ហាញសក្ខីកម្មពីអត្ថិភាពនៃគោលនយោបាយផ្សេងៗនៅទូទាំងប្រទេស រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនៅទូទាំងប្រទេស រចនាសម្ព័ន្ធប្រាស្រ័យទាក់ទងនៅទូទាំងប្រទេស រចនាសម្ព័ន្ធយោធានៅទូទាំងប្រទេស និងអត្ថិភាពនៃការវាយប្រហារយ៉ាងទូលំទូលាយ និងជាប្រព័ន្ធទៅលើប្រជាជនស៊ីវិលកម្ពុជា ក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ អាស្រ័យហេតុនេះ សូមជូនសេចក្តីសន្និដ្ឋានថា ជាពិសេស ដោយគិតដល់ជំហររបស់មេធាវីការពារក្តីដែលមិនបានកំណត់ រហូតទៅដល់អង្គហេតុនានាដែលទាក់ទងនឹងរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ, គោលនយោបាយ និងឧក្រិដ្ឋកម្មនានា ដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ជាការត្រឹមត្រូវ សហព្រះរាជអាជ្ញាគួរតែត្រូវបានផ្តល់ឲ្យនូវឱកាសសមស្របមួយ ដើម្បីលើកឡើងអំពីការចោទប្រកាន់ទាំងនោះ តាមរយៈការយល់ព្រមទទួលយកនូវភស្តុតាងនានាដែលស៊ីសង្វាក់គ្នា។ ការធ្វើដូច្នេះ គឺអង្គជំនុំជម្រះនឹង “រក្សាការពារបាននូវផលប្រយោជន៍របស់ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាសច្ចៈភាពផ្លូវច្បាប់ និងដំណើរការនីតិវិធីប្រកបដោយតម្លាភាព” ដូចដែលបានតម្រូវនៅក្នុងវិធាន២១(១)[52]។

## ភាពឆាប់រហ័ស

៣៥- ខណៈដែលអង្គជំនុំជម្រះមានការទទួលខុសត្រូវ ដើម្បីធានាថា សវនាការមានភាពត្រឹមត្រូវនោះ គឺត្រូវតែធានាថា សវនាការនេះមានភាពឆាប់រហ័សផងដែរ។ ដូចបានបញ្ជាក់ខាងលើ ឯកសារភាគច្រើនមានរួចជាស្រេចជាបីភាសារបស់អង្គជំនុំជម្រះហើយ ធនធានដែលបានតម្រូវដើម្បីបកប្រែឯកសារ

---

[51] *រដ្ឋអាជ្ញា ទល់នឹង Delalić និងគូកន,* សំណុំរឿងលេខ IT-96-21-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ថ្ងៃទី ២០ កុម្ភៈ ២០០១ ត្រង់កថាខណ្ឌទី៤៥៨។

[52] វិធាន២១(១)បានចែងថា៖ “…ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ដើម្បីការពារជានិច្ចដល់ផលប្រយោជន៍របស់….ជនជាប់ចោទ *និង* ជនរងគ្រោះ និងដើម្បីធានាអំពីសច្ចៈភាពផ្លូវច្បាប់ និងដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសនៃអង្គជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង”។ (សង្កត់ន័យដោយអក្សរទ្រេត)

នៅសល់ គឺមានតិចតួចណាស់។ ប្រតិចារឹកសវនាការ និងកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស ត្រូវបានបកប្រែទាំងស្រុងរួចហើយ លើកលែងតែឯកសារមួយគឺ ពាក្យបណ្តឹង ខណៈដែល មិនបានបកប្រែទាំងស្រុងនោះ ត្រូវបានសង្ខេបជាភាសាអង់គ្លេសស្ទើរតែទាំងអស់រួចហើយ ការបក ប្រែសេចក្តីថ្លែងដែលនៅសល់ មានមិនច្រើនទេ។

៣៦- គេបានសន្និដ្ឋានថា ពេលវេលាតម្រូវឱ្យភាគីនានាលើកឡើងពីការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំឱ្យទទួលយក គឺមិនទំនងជាវែងទេ។ ភាគីនានានឹងអាចដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងឯកសារទាំងនោះបាន ហើយបទពិសោធន៍បង្ហាញថា ការជជែកគ្នាពីឯកសារនាំឱ្យមានការជំទាស់ជាទូទៅដែលបានអនុវត្តចំពោះឯកសារទាំងអស់ មិនមែនជាការជំទាស់ទៅនឹងឯកសារជាក់លាក់នោះទេ ហើយជាញឹកញាប់ មាការទាក់ទងនឹងសំអាងពីទម្ងន់ដែលគេបានដាក់ទៅលើឯកសារទាំងនោះមិនទាក់ទងនឹងការទទួលយកឯកសារទេ។ ដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពថា ធនធានរបស់អង្គជំនុំជម្រះដែលបានតម្រូវឱ្យមានដើម្បីពិចារណាពីការទទួលយកឯកសារទាំងនេះ គឺមិនទំនងជាសំខាន់ប៉ុន្មានទេ ដោយឡែក កាលណាគេតម្រូវឱ្យភាគីនានាដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរជាការបន្ថែមទៅលើពេលវេលាដែលបានកំណត់ជាក់លាក់ ក្នុងការធ្វើការជំទាស់ដោយផ្ទាល់មាត់។

៣៧- បន្ថែមលើនេះ ទោះបីចំនួនសក្ខីកម្មផ្ទាល់មាត់ដែលអង្គជំនុំជម្រះត្រូវស្តាប់ គឺបានកម្រិតរួចហើយដោយសារហេតុផលនៃការអនុវត្តក៏ដោយ ក៏ការទទួលយកភ័ស្តុតាងដែលស៊ីសង្វាក់គ្នានេះ កាត់បន្ថយបានយ៉ាងច្រើននូវចំនួនសក្ខីកម្ម ដោយមិនបានធ្វើឱ្យអង្គជំនុំជម្រះខ្វះភ័ស្តុតាង ក្នុងការបំពេញករណីយកិច្ចរបស់ខ្លួននៅក្នុងការស្វែងរកការពិតនៃការចោទប្រកាន់ ដែលមាននៅក្នុងដីកាដំណោះស្រាយនោះទេ។ ជាលទ្ធផល សវនាការនឹងមានរយៈពេលខ្លីជាង។ នៅក្នុងការពិនិត្យសារឡើងវិញនូវឯកសារដែលគេបានដាក់ថាជាភ័ស្តុតាងដែលស៊ីសង្វាក់គ្នានោះ សហព្រះរាជអាជ្ញាប៉ុនប៉ងពិចារណាពីករណីយកិច្ចរបស់អង្គជំនុំជម្រះក្នុងការ "បង្កើតឱ្យមាននូវតុល្យភាពមួយសមស្របរវាងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ និងប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ជាពិសេស ទាក់ទិនទៅនឹងដំណើរការឆាប់រហ័សនៃការជំនុំជម្រះក្តី"[53]។

[53] **E96/7** សេចក្តីសម្រេច ត្រង់កថាខណ្ឌទី២០។ *សូមអានផងដែរ* ច្បាប់ស្តីពីការបង្កើត អវតក, មាត្រា៣៣ថ្មី។

## ៤. ដំណោះស្រាយដែលបានស្នើសុំ

៣៨- ចំពោះមូលហេតុដូចបានរៀបរាប់ខាងលើ សូមស្នើដាក់ឯកសារដែលបានកំណត់អត្តសញ្ញាណនៅក្នុង **ឧបសម្ព័ន្ធ១** និង**២** គឺអាចទទួលយកបាន ស្របតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ និងមានភវនីយភាពក្នុងការបង្ហាញពីបទចោទនានាដែលជាប្រធានបទនៃសំណុំរឿង០០២/០១។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង៖

(ក) ទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងសក្ខីកម្មសវនាការ ដែលបានកំណត់អត្តសញ្ញាណនៅក្នុង**ឧបសម្ព័ន្ធ១** ដល់**២** ធ្វើជាភ័ស្តុតាង និងដាក់លេខជា E3 បើការណ៍នេះនៅមិនទាន់បានធ្វើនៅឡើយ, និង

(ខ) ពឹងផ្អែកលើកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងសក្ខីកម្មសវនាការ ដែលបានកំណត់អត្តសញ្ញាណនៅក្នុង**ឧបសម្ព័ន្ធ១** ដល់**២** ធ្វើជាភ័ស្តុតាងត្រួតដែលស៊ីសង្វាក់គ្នានឹងសក្ខីកម្មដោយផ្ទាល់មាត់ដែលបានស្ដាប់នៅពេលសវនាការ ដើម្បីកំណត់បទចោទនានាប្រឆាំងនឹងជនជាប់ចោទនៅក្នុងសំណុំរឿង០០២/០១៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | [signature] |